អគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ
នាយកដ្ឋានអភិរក្សសុរិយោដី
ចូល
លេខ: ១៦១៧៨៩
ថ្ងៃ ០៧.១២.០៦
បញ្ជូន ៥ ១០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ

លេខ ២៧៤ ស/សជភ.

ភ្នំពេញ . ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០០៦

# សេចក្តីណែនាំ

## ស្តីពី

## គោលការណ៍ នីតិវិធី និងរូបមន្ត លេខាចារិកទាក់ទងនឹងទ្រព្យសហភោគី ឬកម្មសិទ្ធិករអវិភាគ

ការងារកាន់កាប់ឯកសារសុរិយោដី តម្រូវឱ្យមានគោលការណ៍ រូបមន្ត និងនីតិវិធីច្បាស់លាស់ ដើម្បីធានាសិទ្ធិរបស់បុគ្គលម្ចាស់សិទ្ធិផង និងឱ្យមានការឯកភាពគ្នាក្នុងការអនុវត្តផង ។ ក្នុងគោលដៅនេះ ការវិវត្តប្រែប្រួលខាងសតិអារម្មណ៍របស់មនុស្ស និងសង្គម ចេះតែប្រព្រឹត្តទៅឥតឈប់ឈរ ដែលធ្វើរូបមន្ត គោលការណ៍ និងនីតិវិធីដែលមានពីមុន មិនអាចឆ្លើយតបបានគ្រប់គ្រាន់ ហើយទាមទារឱ្យមានការដោះស្រាយបន្ថែម ទៅតាមអ្វីដែលជាសេចក្តីត្រូវការថ្មីៗ ។ ករណីជាក់ស្តែងកើតឡើងពេលនេះ គឺទាក់ទងនឹងទ្រព្យសហភោគី ឬទ្រព្យកម្មសិទ្ធិករអវិភាគ ។

**ករណីទី១** - បុគ្គលម្នាក់មានអចលនទ្រព្យជាដីផ្ទាល់ខ្លួនមួយក្បាល មានប័ណ្ណសំគាល់សិទ្ធិត្រឹមត្រូវ ក្រោយមកបុគ្គលនេះចង់ដាក់ទ្រព្យនេះទៅជាទ្រព្យសហភោគី ឬកម្មសិទ្ធិអវិភាគវិញ តើខាងជំនាញត្រូវអនុវត្តគោលការណ៍អ្វី រូបមន្តណា ហើយតាមនីតិវិធីណាមួយ ? ។

ឧទាហរណ៍ ឈ្មោះ ក មានទ្រព្យផ្ទាល់ខ្លួនជាដីមួយក្បាល ឬច្រើនក្បាល ហើយមានបំណងដាក់ទ្រព្យ ឬដីទាំងនេះ ទៅជាទ្រព្យរួមគ្នាជាមួយបុគ្គលផ្សេងៗ ម្នាក់ទៀត ឬច្រើននាក់ អាចឈ្មោះ ខ ឬ គ... ដែលមានចំណែកស្មើៗគ្នា ឬមិនស្មើគ្នាគិតជាភាគរយ ។

**១_គោលការណ៍ :** ផ្អែកលើគោលការណ៍នៃប្រភេទទ្រព្យ ដែលក្នុងករណីនេះ មានទំនាក់ទំនងរវាងប្រភេទទ្រព្យពីរខុសគ្នា គឺទីមួយ ជា**ទ្រព្យផ្ទាល់ខ្លួន**របស់បុគ្គល ឬរបស់គ្រួសារមួយ ហើយទីពីរ ជាទ្រព្យរួមគ្នារវាងបុគ្គលពីរ ឬគ្រួសារពីរ ដែលគេឱ្យឈ្មោះថាជា**ទ្រព្យសហភោគី** ឬជាទ្រព្យកម្មសិទ្ធិករអវិភាគ ។

២-នីតិវិធី : ដូចគ្នានឹងការដាក់ទ្រព្យចូលក្នុងក្រុមហ៊ុន គ្រាន់តែករណីនេះវាគ្មានលក្ខន្តិកៈដែលក្នុងនោះគេបានប្រកាសភាគហ៊ុនទេ វាជាការយល់ព្រមរបស់ភាគីម្ចាស់ទ្រព្យ ឱ្យភាគីដែលចង់ចូលហ៊ុន ដាក់ប្រាក់ឱ្យខ្លួនតាមតម្លៃពាក់កណ្ដាល ឬសមាមាត្រ ធៀបទៅនឹងតម្លៃដីទាំងមូល ។ ពិនិត្យលើឯកសារផ្លូវការដែលមាន ពុំឃើញឯកសារណាមួយដែលអាចឱ្យភាគីចូលជាទ្រព្យសហភោគី ឬទ្រព្យកម្មសិទ្ធិករអវិភាគបំពេញ ហើយអាចយកទៅប្រថាប់ត្រាបង់ពន្ធបាននោះឡើយ ។ ដូច្នេះ វិធីមានតែមួយ គឺធ្វើលិខិតលក់ផ្ដាច់ ដោយអ្នកលក់ គឺម្ចាស់ទ្រព្យផ្ទាល់ ឬគ្រួសារ ឯអ្នកទិញ គឺម្ចាស់ទ្រព្យជាសហភោគី ឬ កម្មសិទ្ធិករអវិភាគ រួចបង់ពន្ធប្រថាប់ត្រា ហើយយកមកចុះបញ្ជីតែម្ដង ទើបបាន ។

៣-រូបមន្ត : ក

ក និង ខ

( ទ្រព្យសហភោគី ឬទ្រព្យកម្មសិទ្ធិករអវិភាគ )

**ចរន្តការ :** ឈ្មោះ ក ( ទ្រព្យផ្ទាល់ ) លក់ផ្ដាច់ឱ្យ ក + ខ ( ទ្រព្យសហភោគី ឬទ្រព្យកម្មសិទ្ធិករអវិភាគ ) តាមសំបុត្រចុះថ្ងៃទី....

**ករណីទី២**-បុគ្គលពីរនាក់ ឬពីរគ្រួសារ បានសំរេចចូលដើមទុនគ្នា ទិញដី ឬអចលនវត្ថុមួយ ទុកប្រើប្រាស់ ឬទុកលក់យកចំណេញចែកគ្នា ។

**ក**-ប្រសិនបើ បុគ្គលដែលទាំងពីរជាបុគ្គលទោល ( លីវ ឬមេម៉ាយ ពោះម៉ាយ ) ដូចគ្នា រូបមន្តនៃការសរសេរក្នុងកំណត់ហេតុអង្កេតដី ឬទំរង់បែបបទនៃការប្រមូលទិន្នន័យ ក្នុងបញ្ជីដី និងក្នុងប័ណ្ណដី រូបមន្តដែលមានអាចអនុវត្តបាន ។

**ខ**-តែប្រសិនបើ បុគ្គលម្ខាង ឬទាំងពីរមានចំណងអាពាហ៍ពិពាហ៍ រូបមន្តនៃការសរសេរក្នុងឯកសារ ពិតជាត្រូវកំណត់ផ្សេងពីចំណុច ( ក ) ទើបអាចអនុវត្តបាន ។

**រូបមន្ត :**

១- បុគ្គលម្នាក់លីវ ឯបុគ្គលម្នាក់ទៀតមានចំណងអាពាហ៍ពិពាហ៍

ឧទាហរណ៍ : ច

ក ( លីវ ឬមេម៉ាយ )

និង

ខ ( BC ល )

**ចរន្តការ :** ច លក់ផ្ដាច់ឱ្យ ក ( លីវ ឬមេម៉ាយ ) និង ខ ( BC ល ) តាមសំបុត្រចុះថ្ងៃទី...

នៅពេលទ្រព្យសហភោគី ឬទ្រព្យកម្មសិទ្ធិករអវិភាគលក់បន្ត អ្នកលក់ត្រូវផ្តិតមេដៃបីនាក់ គឺ ភ . ខ និង ឍ ។

២-បុគ្គលទាំងពីរ ស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍

ឧទាហរណ៍ : ជ

ភ ( BC ត )

និង

ឌ ( BC ធ )

ចរន្តការ : ជ លក់ផ្តាច់ឱ្យ ភ ( BC ត ) និង ឌ ( BC ធ ) តាមសំបុត្រចុះថ្ងៃ ....

នៅពេលសហភោគីលក់បន្ត ក្នុងលិខិតលក់ត្រូវផ្តិតដៃ អ្នកលក់ពីរនាក់ប្តីប្រពន្ធទាំងពីរគូ គឺ ភ និង ត - ឌ និង ធ ។

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

លឹម វ៉ាន់